**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៦ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រី ទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យកសិកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសភាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតខុទ្ទកាល័យឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រី ទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យកសិកម្ម ចំណុះខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១. ឯកឧត្តមបណ្ឌិត **គង់ ច័ន្ទតារារ័ត្ន** | ប្រធាន |
| ២. ឯកឧត្តម **ជាង គាំបូជូស៊ីន** | អនុប្រធាន |



https://www.moj.gov.kh/kh/law-regular

៣. ឯកឧត្តម **ថោង ចំរើន** អនុប្រធាន

៤. លោក **គង់ ទិសាល** សមាជិក

៥. លោកស្រី **ឆេង ដារ៉ា** សមាជិក

៦. លោក **ជុន ចេស្តា** សមាជិក

៧. លោក **ខាន់ សែនរិទ្ធិ** សមាជិក

ការតែងតាំង និងការផ្លាស់ប្តូរសមាសភាពនៃក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រី ទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យកសិកម្ម ត្រូវធ្វើឡើងតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដោយយោងតាមសំណើរបស់ប្រធានក្រុមការងារ។

ក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រី ទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យកសិកម្ម អាចបង្កើតក្រុមការងារចំណុះតាមការចាំបាច់ តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដោយយោងតាមសំណើរបស់ប្រធានក្រុមការងារពិសេស ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

**ប្រការ២ ..**

ក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រី ទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យកសិកម្ម មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ជាសេនាធិការជូននាយករដ្ឋមន្ត្រីក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យកសិកម្ម
- ផ្តល់យោបល់ និងលើកវិធានការ ជូននាយករដ្ឋមន្ត្រីលើសកម្មភាព និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យកសិកម្ម
- ធ្វើការជាមួយក្រសួង-ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងបណ្តាភាគីពាក់ព័ន្ធនឹងការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យកសិកម្ម ដើម្បីទទួលបានទិន្នន័យ ព័ត៌មាន និងរបាយការណ៍
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយករដ្ឋមន្ត្រី។

**ប្រការ៣ ..**

ក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រី ទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យកសិកម្ម មានថវិកាសម្រាប់ដំណើរការការងាររបស់ខ្លួន ក្នុងកញ្ចប់ថវិការបស់ឧទ្ទកាល័យនាយករដ្ឋមន្ត្រី។

**ប្រការ៤ ..**

សេចក្តីសម្រេចលេខ ១៥០ សសរ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើតក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងវិធានការអាទិភាពក្នុងវិស័យកសិកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។



https://www.moj.gov.kh/kh/law-regular

**ប្រការ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៤កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular